【កំណៃណឆ្នាំ2025】

ឧទាហរណ៍ល្អប្រសើរនៃការទទួលជនបរទេសជំនាញជាក់លាក់សម្រាប់វិស័យកសិកម្ម

# ក្រុមហ៊ុន SHIMOMURA CHIKUSAN Ltd.

## ~ គ្រប់គ្រងកិច្ចការប្រចាំថ្ងៃក្រោមការដឹកនាំរបស់ពលករជំនាញជាក់លាក់កម្រិត2 និងផ្តួចផ្តើមធ្វើឲ្យមើលឃើញការរីកចម្រើនក្នុងអាជីព ~

| | |
|---|---|
| ព័ត៌មានមូលដ្ឋាន<br>ទីតាំង៖ ក្រុងអូប៊ី ខេត្តអែឈិ<br>ការចិញ្ចឹមសត្វ៖ ផលិតពីដើមដល់ចប់នូវពូជគោពោមខ្មៅ នៅកសិដ្ឋានក្រុមហ៊ុនយើង ចាប់ពីបង្កាត់ពូជ រហូតដល់ចិញ្ចឹមបំប៉ន និងកែច្នៃសាច់សម្រាប់ហូបជាដើម ហើយបញ្ចេញទំនិញទៅទូទាំងប្រទេសជប៉ុន និងក្រៅប្រទេស ប្រហែល 1,500 ក្បាល ក្នុងមួយឆ្នាំ<br>ការចិញ្ចឹមសំខាន់ៗ៖ គោយកសាច់ 1,190 ក្បាល គោយកទឹកដោះ 12 ក្បាល (ប្រហែល 4,800ក្បាល នៅសម្ព័ន្ធទាំងមូល)<br>សមាសភាពបុគ្គលិក (នៅពេលស្ទង់មតិ)៖ ជនជាតិជប៉ុនចំនួន8នាក់ កម្មសិក្សាហ្វឹកហ្វឺនជំនាញនិងជំនាញជាក់លាក់កម្រិត1ចំនួន5នាក់ +ជំនាញជាក់លាក់កម្រិត2ចំនួន1នាក់ |  |

<table>
<tr><td>(ជនជាតិវៀតណាមទាំងអស់)</td><td></td></tr>
<tr><td colspan="2">កិច្ចផ្តួចផ្តើមពិសេសដោយឡែករបស់ស្ថាប័នទទួលចូល៖ ការបង្កើតយន្តការនៃការរីកចម្រើនក្នុងអាជីព<br>① យើងត្រូវបានបង្ខំឲ្យចាំបាច់ត្រូវតែដំឡើងប្រាក់ឈ្នួល ដោយសារតែការប្រកួតប្រជែងជាមួយឧស្សាហកម្មផ្សេងទៀតក្នុងការរកបាននូវធនធានពីបរទេស។<br>② ខណៈពេលដែលកំពុងពិចារណាពីរបៀបដំឡើងប្រាក់ឈ្នួល នៅពេលបច្ចុប្បន្ននេះ យើងកំពុងសាងសង់យន្តការនៃការរីកចម្រើនក្នុងអាជីព។<br>③ យន្តការនេះ មានបញ្ជាក់ពីខ្លឹមសារការងារ រយៈពេលដែលត្រូវការ និងចំនួនប្រាក់ឈ្នួលដំឡើងនៅពេលដែលអាចធ្វើការងារនោះបានយ៉ាងមានស្ថិរភាព។</td></tr>
<tr><td colspan="2">【កិច្ចសម្ភាសជាមួយស្ថាប័នទទួលចូល (ប្រធានផ្នែកទូទៅ និស៊ិមឹរ៉ា)】<br>① សូមរៀបរាប់អំពីការបង្កើតយន្តការដែលកត់ត្រាខ្លឹមសារការងារ និងម៉ោងធ្វើការ សម្រាប់បុគ្គលិកបរទេសម្នាក់ៗ ក្នុងទម្រង់ជាកិច្ចផ្តួចផ្តើមសម្រាប់ការរីកចម្រើនក្នុងអាជីព។<br>(សារតារ) ពីមុន យើងអាចជួលបុគ្គលិកដោយប្រើប្រាក់ឈ្នួលអប្បបរមាបាន ប៉ុន្តែបច្ចុប្បន្ននេះ វាមានការពិបាកដោយសារតែការប្រកួតប្រជែងជាមួយឧស្សាហកម្មផ្សេងទៀត។ ដូច្នេះ ខណៈពេលដែលកំពុងពិចារណាថាត្រូវបង្កើនប្រាក់ឈ្នួលតាមរបៀបណា យើង</td></tr>
</table>

កំពុងបង្កើតយន្តការសម្រាប់ការរីកចម្រើនក្នុងអាជីពរបស់បុគ្គលិក។

(ចំណុចកែលម្អមកទល់ពេលនេះ) ដំបូង យើងបានបង្កើតបញ្ជីមួយដែលបង្ហាញថានរណាត្រូវអនុវត្តការងារអ្វី និងដាក់ឲ្យគ្រប់គ្នាអាចមើលឃើញ។ ការធ្វើបែបនេះ ក៏មានឥទ្ធិពលបន្ទាប់បន្សំក្នុងការលុបបំបាត់អារម្មណ៍មិនស្មើភាពគ្នាទាក់ទងនឹងបន្ទុកការងារក្នុងចំណោមបុគ្គលិកផងដែរ។ លើសពីនេះ ក្នុងករណីមានការយឺតយ៉ាវក្នុងការងារ បុគ្គលិកផ្សេងទៀតអាចចូលបំពេញត្រង់នោះបាន ហើយសម្រាប់អ្នកស្នើសុំ ពេលនេះគេអាចឈប់សម្រាកពីរថ្ងៃក្នុងមួយសប្តាហ៍បានហើយ។ ខ្ញុំជឿថានេះជារឿងកម្រមានណាស់នៅក្នុងវិស័យដែលត្រូវធ្វើការជាមួយសត្វមួយនេះ។

(យន្តការនៃការរីកចម្រើនក្នុងអាជីពដែលកំពុងបង្កើត) យើងកំពុងបង្កើតយន្តការដែលមានបញ្ជាក់ពីខ្លឹមសារការងារ រយៈពេលដែលត្រូវការ និងចំនួនប្រាក់ឈ្នួលដំឡើងតាមរយៈសមត្ថភាពការងារនិងការវាយតម្លៃ នៅពេលអាចធ្វើការងារនោះបានយ៉ាងមានស្ថិរភាព។ យើងចង់បង្ហាញវាដល់បុគ្គលិកទាំងអស់។ យើងក៏កំពុងពិចារណាបញ្ចូលតម្រូវការភាសាជប៉ុនទៅក្នុងយន្តការនេះសម្រាប់បុគ្គលិកបរទេស ដើម្បីលើកទឹកចិត្តក្នុងការរៀនភាសាជប៉ុន។ យើងមិនបែងចែករវាងបុគ្គលិកជាជនជាតិជប៉ុន និងបុគ្គលិកជាជនបរទេសទេ ប៉ុន្តែចំពោះភាសាជប៉ុនមួយ យើងមានអារម្មណ៍ថា ចាំបាច់ត្រូវមានកិច្ចផ្តួចផ្តើមក្នុងការលើកទឹកចិត្តក្នុងការរៀនភាសាជប៉ុនសម្រាប់បុគ្គលិកជាជនបរទេស។

② សូមប្រាប់យើងអំពី អ្នកនាង ហ្វាង ដែលជាពលករជំនាញជាក់លាក់កម្រិត2។

នៅពេលនោះ មិនទាន់មានប្រព័ន្ធជំនាញជាក់លាក់នៅឡើយទេ ដូច្នេះបន្ទាប់ពីបាន

បញ្ចប់កម្មសិក្សាហ្វឹកហ្វឺនជំនាញនៅក្រុមហ៊ុនយើង គាត់បានត្រឡប់ទៅប្រទេសកំណើតវិញ។ នៅពេលដែលយើងបានឮថា ប្រព័ន្ធជំនាញជាក់លាក់នឹងចាប់ផ្តើម យើងបានទៅប្រទេសវៀតណាមដើម្បីរើសគាត់ចូល ប៉ុន្តែគាត់ត្រូវបានតម្រូវឲ្យរង់ចាំចូលប្រទេសជប៉ុនដោយសារជំងឺរាតត្បាតកូរ៉ូណា។ ចំពោះការប្រឡងជំនាញជាក់លាក់កម្រិត2 គាត់បានរៀនដោយមើលសៀវភៅពុម្ពជាដើមជាភាសាជប៉ុនដោយខ្លួនឯង ហើយក្រុមហ៊ុនបានផ្តល់ការគាំទ្រផ្នែកសម្ភារឧបករណ៍ ដូចជាព្រីនសៀវភៅពុម្ពដើម។ គាត់បានប្រឡងជាប់ក្នុងខែមីនា ឆ្នាំនេះ (ឆ្នាំទី៣នៃការចូលប្រទេសជប៉ុនក្នុងទម្រង់ជាជំនាញជាក់លាក់)។ បច្ចុប្បន្ននេះ ក្នុងនាមជាអ្នកគ្រប់គ្រងនៅទីតាំងផ្ទាល់ គាត់ដឹកនាំបុគ្គលិកនៅទីតាំងផ្ទាល់ ដោយរួមទាំងបុគ្គលិកជនជាតិជប៉ុនផងដែរ។ យើងគិតថា គាត់ពិតជាពូកែណាស់ ព្រោះគាត់អាចដឹកនាំអ្វីគ្រប់យ៉ាងដែលក្រុមហ៊ុនចង់ធ្វើ។

【កិច្ចសម្ភាសជាមួយ អ្នកនាង កៅ ទៀន ហ្វុង (ជំនាញជាក់លាក់កម្រិត2)】



រូបថតអ្នកនាង ហ្វុង

① ហេតុអ្វីបានជាអ្នកមកធ្វើការនៅប្រទេសជប៉ុន? តើអ្នកមានគម្រោងធ្វើការក្នុងប្រទេសជប៉ុនយូរប៉ុណ្ណា?

→ក្រោយពីបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ខ្ញុំបានធ្វើការប្រហែល2ឆ្នាំក្នុងប្រទេសកំណើតរបស់ខ្ញុំ។ ខ្ញុំបានប្រឡងជាប់តេស្តភាសាជប៉ុនកម្រិតN2 ហើយខ្ញុំមានបំណងធ្វើការនៅក្រៅប្រទេសដើម្បីរកប្រាក់។

ក្រោយបញ្ចប់កម្មសិក្សាហ្វឹកហ្វឺនជំនាញនៅក្រុមហ៊ុន SHIMOMURA CHIKUSAN ខ្ញុំបានត្រលប់ទៅវិញ ហើយចំណាយពេល4ឆ្នាំក្នុងប្រទេសវៀតណាម។ ដោយសារមានការស្នើសុំយ៉ាងខ្លាំងពីលោកប្រធានក្រុមហ៊ុន ខ្ញុំក៏បានសម្រេចចិត្តមកប្រទេសជប៉ុនសាជាថ្មី និងធ្វើការក្នុងទម្រង់ជាជំនាញជាក់លាក់។

ក្រុមហ៊ុនយើង ផលិតសាច់គោលេខមួយក្នុងប្រទេសជប៉ុន ហើយខ្ញុំចង់ធ្វើការងារនេះ។

② សូមរៀបរាប់អំពីការងារដែលអ្នកធ្វើ។

→ខ្ញុំធ្វើការងារដែលពាក់ព័ន្ធនឹងការចិញ្ចឹម និងការផលិតគោជប៉ុនពោមខ្មៅ ហើយដោយសារខ្ញុំចេះទាំងភាសាជប៉ុន និងភាសាវៀតណាម ខ្ញុំក៏ផ្តល់ដំបូន្មាន និងជួយមើលបុគ្គលិកទាំងផ្នែកការងារ និងផ្នែករស់នៅជាដើមផងដែរ។ ដោយសារត្រូវធ្វើការជាមួយសត្វ ដូច្នេះយើងក៏ត្រូវយកចិត្តទុកដាក់ចំពោះសុវត្ថិភាពនិងអនាម័យការងារផងដែរ។

③ តើអ្នកមានទំនាក់ទំនងជាមួយអ្នកនៅក្នុងមូលដ្ឋានរបស់អ្នកដែរឬទេ?

→ខ្ញុំចូលរួមយ៉ាងសកម្មក្នុងថ្នាក់រៀនភាសាជប៉ុនដែលរៀបចំដោយរដ្ឋបាលមូលដ្ឋាន និងកម្មវិធីទំនាក់ទំនងក្នុងមូលដ្ឋាន ដូចជាការលេងវាយសីនិងថ្នាក់រៀនធ្វើម្ហូបជាដើម ហើយខ្ញុំពិតជារីករាយខ្លាំងណាស់។

④ តើអ្នករៀនបែបណាខ្លះដើម្បីអាចប្រឡងជាប់ជំនាញជាក់លាក់កម្រិត2?

→ខ្ញុំរៀនដោយមើលសៀវភៅពុម្ពដែលទាក់ទងនឹងជំនាញកម្រិត2ក្នុងវិស័យកសិកម្មដែលមាននៅលើគេហទំព័រ។ ដោយសារការងារនេះត្រូវធ្វើជាមួយសត្វ ដូច្នេះក៏មានកន្លែងខ្លះដែលពិបាកយល់បើមើលតែសៀវភៅពុម្ព ហើយចំពោះកន្លែងណាដែលខ្ញុំមិនយល់ ខ្ញុំ

ស្រាវជ្រាវដោយខ្លួនឯងដោយប្រើស្មាតហ្វូន និងខិតខំស្វែងយល់គ្រប់រឿងទាំងអស់។

⑤ តើអ្នកពេញចិត្តនឹងប្រាក់ឈ្នួលរបស់អ្នកដែរឬទេ?

→នៅពេលចូលមកប្រទេសជប៉ុនសាជាថ្មី យើងបានសម្រេចដោយពិភាក្សាជាមួយលោកប្រធានក្រុមហ៊ុន។ នៅក្រុមហ៊ុនយើង ជាមូលដ្ឋាន ជនជានមកពីបរទេសទទួលប្រាក់ឈ្នួលប្រចាំម៉ោង ប៉ុន្តែសម្រាប់ជំនាញជាក់លាក់កម្រិត2 ដូចគ្នានឹងបុគ្គលិកជាជនជាតិជប៉ុនដែរ គឺទទួលប្រាក់ឈ្នួលប្រចាំខែ ហើយខ្ញុំពិតជាពេញចិត្តណាស់។

⑥ តើអ្នកមានគោលដៅអ្វីក្នុងពេលអនាគត? តើអ្នកគិតយ៉ាងណាចំពោះអនាគតនៅក្នុងប្រទេសកំណើតរបស់អ្នក?

→ខ្ញុំចង់ធ្វើការឲ្យបានយូរតាមដែលអាចធ្វើទៅបាន ហើយខ្ញុំចង់បើកភោជនីយដ្ឋាននៅក្នុងប្រទេសកំណើតរបស់ខ្ញុំ។ ប្តីនិងកូនរបស់ខ្ញុំកំពុងរស់នៅប្រទេសកំណើត ហើយបើសិនជាអាច ខ្ញុំចង់ហៅពួកគេមករស់នៅជាមួយគ្នា។

⑦ តើអ្នកមានដំបូន្មានអ្វីដល់សិស្សប្អូនដែរឬទេ?

→សំខាន់ត្រូវរៀនភាសាជប៉ុន។ ទន្ទឹមគ្នានឹងភាសាជប៉ុន ខ្ញុំចង់ឲ្យអ្នកចូលរួមក្នុងការផ្លាស់ប្តូរសម្រាប់ជនបរទេសជាដើម ហើយរៀនពីជីវិតរស់នៅ និងវប្បធម៌ជប៉ុន។

【"សារជូនទៅជនជាតិវៀតណាមដែលមកក្នុងពេលអនាគត" (បកប្រែពីភាសាវៀតណាម)】

① ខ្ញុំឈ្មោះ ហ្សុង។ ខ្ញុំមកពីខេត្តក្វាងទ្រី។

ជនជាតិជប៉ុនពិតមានវិន័យតឹងរ៉ឹងណាស់ ប៉ុន្តែខ្ញុំបានរៀនភាសាជប៉ុនយ៉ាងយកចិត្ត

ទុកដាក់ ដើម្បីជីវភាពរស់នៅ និងការងាររបស់ខ្ញុំ ហើយខ្ញុំបានស៊ាំនឹងការរស់នៅក្នុងប្រទេសជប៉ុនហើយ។ ជីវិតក្នុងប្រទេសជប៉ុន មានភាពល្អប្រសើរណាស់។ វាស្អាត ហើយម្ហូបអាហារមានសុវត្ថិភាពនិងអនាម័យ ហើយប្រជាជនមានសុជីវធម៌ណាស់។

② ខ្ញុំកំពុងធ្វើការនៅក្រុមហ៊ុន SHIMOMURA CHIKUSAN ដែលមានទ្រង់ទ្រាយនៃការចិញ្ចឹមសត្វធំជាងគេក្នុងខេត្តអែឈិ។

អ្នកទាំងអស់គ្នាប្រហែលជាស្គាល់ "សាច់គោកូបេ" ហើយ ប៉ុន្តែក្រៅពី "សាច់គោកូបេ" នៅក្នុងប្រទេសជប៉ុន យើងក៏មានការចិញ្ចឹមគោពូជល្បីផ្សេងទៀតដែលមានគុណភាពស្រដៀងគ្នាផងដែរ។ គោនេះអាចចិញ្ចឹមបានតែនៅក្នុងប្រទេសជប៉ុនប៉ុណ្ណោះ។

③ ដូចដែលអ្នកទាំងអស់គ្នាដឹងហើយថា ការងារកសិកម្មមានការលំបាក និងទាមទារច្រើន ប៉ុន្តែបើយើងខិតខំប្រឹងប្រែង យើងនឹងអាចយកឈ្នះលើអ្វីៗគ្រប់យ៉ាង។

វាក៏ជាឱកាសមួយដើម្បីរៀនពីរបៀបធ្វើការ របៀបរស់នៅ និងរបៀបអភិវឌ្ឍខ្លួនផងដែរ។

បន្ទាប់ពីមកដល់ប្រទេសជប៉ុន ខ្ញុំបានក្លាយជាកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ហើយក្រោយមកខ្ញុំបានប្តូរទៅទិដ្ឋាការជំនាញជាក់លាក់កម្រិត1 ហើយបច្ចុប្បន្ននេះ ខ្ញុំមានទិដ្ឋាការជំនាញជាក់លាក់កម្រិត2។ វាជាដំណើរដ៏វែងឆ្ងាយមួយ ហើយឥឡូវនេះ ខ្ញុំអាចធ្វើការជាមួយជនជាតិជប៉ុនបានយ៉ាងធម្មតា។

④ សរុបមក មានលទ្ធភាពច្រើនណាស់។ ប្រសិនបើអ្នកមានឱកាស សូមមកប្រទេសជប៉ុនកុំខាន។ រឿងអស្ចារ្យជាច្រើន កំពុងរង់ចាំអ្នកទាំងអស់គ្នា។